**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរអគ្គិសនីកម្ពុជា**
លេខ១៣០ សណ ៧២អក

# សេចក្តីណែនាំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីគោលការណ៍ និងនីតិវិធីនៃការអនុវត្តអត្រាថ្លៃអនុគ្រោះពិសេស ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ ក្នុងវិស័យកសិកម្ម ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនី ដែលទទួលប្រភពពីបណ្តាញជាតិ

អាជ្ញាធរអគ្គិសនីកម្ពុជា មានកិត្តិយសជម្រាបជូនលោកឧកញ៉ា លោក/លោកស្រី ជាអ្នកកាន់អាជ្ញាបណ្ណផ្គត់ផ្គង់អគ្គិសនី និងអ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្មទាំងអស់ មេត្តាជ្រាបថា ចាប់ពីឆ្នាំ២០១៦ មក ក្រសួងរ៉ែ និងថាមពល បានដាក់ចេញនូវគោលនយោបាយផ្តល់ថ្លៃអនុគ្រោះពិសេស ចំពោះអ្នកប្រើប្រាស់ដែលយកអគ្គិសនីទៅបូមទឹកសម្រាប់ធ្វើកសិកម្ម នៅពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ឲ្យបង់ថ្លៃអគ្គិសនីត្រឹមតែ ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង ប៉ុណ្ណោះ ។ បន្ថែមលើនេះ នៅឆ្នាំ២០២១ ក្រសួងរ៉ែ និងថាមពល បានពង្រីកវិសាលភាពនៃការផ្តល់ថ្លៃអនុគ្រោះពិសេស ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើអគ្គិសនីនៅពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ឲ្យដល់អ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្ម ។ ដូច្នេះ ពេលនេះ ដើម្បីជួយជំរុញការអនុវត្តគោលនយោបាយផ្តល់ថ្លៃអនុគ្រោះពិសេសនេះ ឲ្យកាន់តែរលូន និងមានប្រសិទ្ធភាព អាជ្ញាធរអគ្គិសនីកម្ពុជាកំណត់គោលការណ៍ និងនីតិវិធីនៃការអនុវត្ត ដូចខាងក្រោម ៖

## ក. និយមន័យអ្នកប្រើប្រាស់ប្រភេទកសិកម្ម

អ្នកប្រើប្រាស់ប្រភេទកសិកម្ម គឺទីតាំងទាំងឡាយណាដែលធ្វើសកម្មភាពដូចខាងក្រោម ៖

១. ការដាំដុះ ចិញ្ចឹមសត្វ និងនេសាទ

-ដំណាំកសិឧស្សាហកម្ម ៖ កៅស៊ូ, ម្រេច, ចេក, អំពៅ និង ស្វាយ ។ល។

-ដំណាំកសិកម្ម ៖ ស្រូវ, ពោត, សណ្តែក, ល្ង, បន្លែនិងផ្លែឈើ, ផ្សិត ។ល។

-ការចិញ្ចឹមសត្វ ៖ គោ, ក្របី, ជ្រូក, មាន់ និង ទា ។ល។

-វារីវប្បកម្ម (ការចិញ្ចឹមសត្វក្នុងទឹក) ៖ ត្រី, កង្កែប, អន្ទង់, ក្រពើ និងបង្កង ។ល។

២. ធ្វើសកម្មភាពបម្រើឲ្យសកម្មភាពក្នុងចំណុច ១ មានដូចជា ការបូមទឹក ការសម្ងួត ការបង្កក ការផលិតជីកសិកម្ម ។ល។


**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

៣. ធ្វើសកម្មភាពកែច្នៃផលិតផលចេញពីសកម្មភាព ក្នុងចំណុច ១ មានដូចជា ម៉ាស៊ីនកិនស្រូវ រោងចក្រកែច្នៃជាគ្រឿងកំប៉ុង រោងចក្រកែច្នៃម្ហូបអាហារ/ភេសជ្ជៈ រោងចក្រផលិតចំណីសត្វ ។ល។

## ខ. លក្ខខណ្ឌនៃការទិញ និងអត្រាថ្លៃលក់

អ្នកប្រើប្រាស់បូមទឹកធ្វើកសិកម្ម និងអ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្ម អាចជ្រើសរើសលក្ខខណ្ឌនៃការទិញ ទៅតាមតម្រូវការប្រើប្រាស់ជាក់ស្តែងរបស់ខ្លួន ដែលមាន៤ប្រភេទ ដូចជា ៖ ១. ការទិញលើតង់ស្យុងមធ្យម (MV), ២. ការទិញលើតង់ស្យុងទាប (LV) ក្រោមត្រង់ស្វូរបស់អ្នកប្រើប្រាស់ ៣. ការទិញលើតង់ស្យុងទាប (LV) ក្រោមត្រង់ស្វូរបស់អ្នកលក់ និងទី៤. ការទិញពីខ្សែបណ្តាញតង់ស្យុងទាបសាធារណៈ ។ លក្ខខណ្ឌនៃការទិញ និងអត្រាថ្លៃលក់ មានដូចខាងក្រោម ៖

១. ការទិញលើតង់ស្យុងមធ្យម (MV) ៖

-ថ្លៃមធ្យម ៖ ០,១៣៧០ ដុល្លារ ក្នុង១គីឡូវ៉ាត់ម៉ោង

-ថ្លៃពេលយប់ ចាប់ពីម៉ោង៩យប់ ដល់ម៉ោង៧ព្រឹក ៖ ថ្លៃ ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង

២. ការទិញលើតង់ស្យុងទាប (LV) ក្រោមត្រង់ស្វូរបស់អ្នកប្រើប្រាស់ ៖

-ថ្លៃមធ្យម ៖ ០,១៤២៤៨ ដុល្លារ ក្នុង១គីឡូវ៉ាត់ម៉ោង

-ថ្លៃពេលយប់ ចាប់ពីម៉ោង៩យប់ ដល់ម៉ោង៧ព្រឹក ៖ ថ្លៃ ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង

៣. ការទិញលើតង់ស្យុងទាប (LV) ក្រោមត្រង់ស្វូរបស់អ្នកលក់៖

-ថ្លៃមធ្យម ៖ ០,១៥០៤៨ ដុល្លារ ក្នុង១គីឡូវ៉ាត់ម៉ោង

-ថ្លៃពេលយប់ ចាប់ពីម៉ោង៩យប់ ដល់ម៉ោង៧ព្រឹក ៖ ថ្លៃ ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង

៤. ការទិញពីខ្សែបណ្តាញតង់ស្យុងទាបសាធារណៈ (LV) ៖

-ថ្លៃមធ្យម ៖ ៧៣០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង

-ថ្លៃពេលយប់ ចាប់ពីម៉ោង៩យប់ ដល់ម៉ោង៧ព្រឹក ៖ ថ្លៃ ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង

អត្រាថ្លៃអគ្គិសនីសម្រាប់អ្នកប្រើប្រាស់ប្រភេទនេះ មានថ្លៃ២ផ្សេងគ្នា គឺទី១. សម្រាប់ថាមពលអគ្គិសនីប្រើប្រាស់នៅពេលយប់ ចាប់ពីម៉ោង៩យប់ ដល់ម៉ោង៧ព្រឹក ត្រូវបង់ថ្លៃ ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង និងទី២. សម្រាប់ថាមពលអគ្គិសនីប្រើប្រាស់ ក្រៅពីម៉ោង៩យប់ ដល់ម៉ោង៧ព្រឹក ត្រូវបង់ថ្លៃដូចការបញ្ជាក់ក្នុងចំណុចទី១, ២, ៣ និងទី៤ ខាងលើ អាស្រ័យទៅតាមលក្ខខណ្ឌនៃការទិញរបស់អ្នកប្រើប្រាស់នីមួយៗ ។ អត្រាថ្លៃអគ្គិសនីនេះ ត្រូវអនុវត្តចំពោះអ្នកប្រើប្រាស់បូមទឹកធ្វើកសិកម្ម និងអ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្ម ដែលកំពុងអនុវត្តថ្លៃមធ្យម ប៉ុណ្ណោះ ។

## គ. នីតិវិធីនៃការស្នើសុំថ្លៃអនុគ្រោះ

ដើម្បីឲ្យទីតាំងអ្នកបូមទឹកធ្វើកសិកម្ម និងអ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្ម ទទួលបានអត្រាថ្លៃអនុគ្រោះពិសេស ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់នៅពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ភាគីពាក់ព័ន្ធត្រូវអនុវត្ត ដូចខាងក្រោម ៖


**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៩៨៩ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

១. ចំពោះទីតាំងប្រើប្រាស់ជាសហគមន៍៖

- សហគមន៍ត្រូវចាត់បុគ្គល១រូប តំណាងសហគមន៍ ហើយបុគ្គលនោះត្រូវដាក់ពាក្យស្នើសុំប្រើប្រាស់អគ្គិសនី/ស្នើសុំប្តូរប្រភេទអ្នកប្រើប្រាស់ ទៅអ្នកផ្គត់ផ្គង់អគ្គិសនីនៅតំបន់នោះ (អគ្គិសនីកម្ពុជា ឬអ្នកផ្គត់ផ្គង់ឯកជន) តាមរយៈអាជ្ញាធរឃុំ/សង្កាត់ ។
- ក្នុងករណីទីតាំងស្នើសុំនោះឋិតក្នុងតំបន់របស់អ្នកផ្គត់ផ្គង់ឯកជន អ្នកផ្គត់ផ្គង់ឯកជនត្រូវស្នើសុំបន្តទៅមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ (ម.អ.ជ.) របស់អគ្គិសនីកម្ពុជា ដើម្បីសុំការឯកភាព ។

២. ចំពោះទីតាំងប្រើប្រាស់ជារូបវន្តបុគ្គល ឬនីតិបុគ្គល ៖

- អ្នកស្នើសុំត្រូវដាក់ពាក្យស្នើសុំប្រើប្រាស់អគ្គិសនី/ស្នើសុំប្តូរប្រភេទអ្នកប្រើប្រាស់ ទៅអ្នកផ្គត់ផ្គង់អគ្គិសនីនៅតំបន់នោះ (អគ្គិសនីកម្ពុជា ឬអ្នកផ្គត់ផ្គង់ឯកជន) ។
- ក្នុងករណីទីតាំងស្នើសុំនោះឋិតក្នុងតំបន់របស់អ្នកផ្គត់ផ្គង់ឯកជន អ្នកផ្គត់ផ្គង់ឯកជនត្រូវស្នើសុំបន្តទៅមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ (ម.អ.ជ.) របស់អគ្គិសនីកម្ពុជា ដើម្បីសុំការឯកភាព ។

៣. គំរូពាក្យស្នើសុំ ៖

- សម្រាប់អ្នកប្រើប្រាស់ឋិតក្នុងតំបន់របស់អគ្គិសនីកម្ពុជា គំរូពាក្យស្នើសុំ មាននៅតាមសាខា រាជធានី/ខេត្ត របស់អគ្គិសនីកម្ពុជា ឬអាចទាញយកពីគេហទំព័ររបស់អគ្គិសនីកម្ពុជា www.edc.com.kh ។
- សម្រាប់អ្នកប្រើប្រាស់ឋិតក្នុងតំបន់របស់អ្នកផ្គត់ផ្គង់អគ្គិសនីឯកជន គំរូពាក្យស្នើសុំ មាននៅតាមទីតាំងរបស់អ្នកផ្គត់ផ្គង់អគ្គិសនីឯកជន ហើយក្នុងករណីអ្នកស្នើសុំប្រើប្រាស់អគ្គិសនីជាអតិថិជនចាស់ ត្រូវស្នើសុំយកតាមគំរូពាក្យស្នើសុំក្នុងឧបសម្ព័ន្ធ "ក" ភ្ជាប់មកជាមួយ ។ អ្នកផ្គត់ផ្គង់អគ្គិសនីឯកជន ត្រូវស្នើសុំបន្តទៅមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ (ម.អ.ជ.) របស់អគ្គិសនីកម្ពុជា ដើម្បីសុំការឯកភាព ដូចមានគំរូពាក្យស្នើសុំក្នុងឧបសម្ព័ន្ធ "ខ និង គ" ភ្ជាប់មកជាមួយ ។

## ឃ. ប្រព័ន្ធនាឡិកាស្ទង់ និងថ្លៃប្រាក់កក់និងប្រាក់ភ្ជាប់ចរន្ត

ដើម្បីឲ្យទីតាំងអ្នកបូមទឹកធ្វើកសិកម្ម និងអ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្ម ទទួលបានអត្រាថ្លៃអនុគ្រោះ ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់នៅពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ភាគីពាក់ព័ន្ធត្រូវអនុវត្ត ដូចខាងក្រោម ៖

១. ចំពោះទីតាំងប្រើប្រាស់ជាសហគមន៍ ៖

- ការតម្លើងប្រព័ន្ធនាឡិកាស្ទង់ និងការកែសម្រួលឬផ្លាស់ប្តូរប្រព័ន្ធនាឡិកាស្ទង់ ទាំង


អាជ្ញាធរអគ្គិសនីកម្ពុជា : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

សម្រាប់អ្នកប្រើប្រាស់ឋិតក្នុងតំបន់របស់អគ្គិសនីកម្ពុជានិងអ្នកផ្គត់ផ្គង់ឯកជនជាបន្ទុករបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ( ម.អ.ជ. ) របស់អគ្គិសនីកម្ពុជា ។

- ពុំមានតម្រូវឲ្យអ្នកប្រើប្រាស់បង់ថ្លៃភ្ជាប់ចរន្ត និងប្រាក់កក់ជានា ឬបង់ប្រាក់កក់ជានាបន្ថែមឡើយ ។

២. ចំពោះទីតាំងប្រើប្រាស់ជារូបវន្តបុគ្គល ឬនីតិបុគ្គល ៖

- អ្នកប្រើប្រាស់ត្រូវបង់ថ្លៃភ្ជាប់ចរន្ត និងប្រាក់កក់ជានា ទៅតាមគោលការណ៍កំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា ។
- ជាធម្មតា ចំពោះអ្នកប្រើប្រាស់ចាស់ នៅពេលស្នើសុំការអនុគ្រោះថ្លៃពិសេសនេះ អាចតម្រូវឲ្យធ្វើការកែសម្រួល ឬផ្លាស់ប្តូរប្រព័ន្ធនាឡិកាស្ទង់ ដើម្បីអាចធ្វើការកត់ត្រាថាមពលអគ្គិសនីប្រើនៅពេលថ្ងៃ និងពេលយប់បាន ។ ប្រសិនបើ ត្រូវធ្វើការកែសម្រួលប្រព័ន្ធនាឡិកាស្ទង់ ដោយពុំផ្លាស់ប្តូរប្រព័ន្ធនាឡិកាស្ទង់ទេ នោះអគ្គិសនីកម្ពុជាជាអ្នកទទួលបន្ទុកកែសម្រួលជូន ដោយពុំមានបង់ថ្លៃចំណាយទេ ។ ផ្ទុយមកវិញ ប្រសិនបើត្រូវធ្វើការផ្លាស់ប្តូរប្រព័ន្ធនាឡិកាស្ទង់ នោះអ្នកប្រើប្រាស់ត្រូវទទួលបន្ទុកចំណាយលើការផ្លាស់ប្តូរទាំងនោះ ។

## ខ. ក្រុមការងារចម្រុះ EAC-EDC សម្រាប់ពន្យល់ និងបំភ្លឺ

អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា បានបង្កើតក្រុមការងារចម្រុះ EAC-EDC (ដែលមានទូរស័ព្ទទំនាក់ទំនងលេខ 077 222 012 / 090 903 311) សម្រាប់ជួយពន្យល់ និងបំភ្លឺបន្ថែមអំពីគោលការណ៍ និងនីតិវិធីនៃការអនុវត្តអត្រាថ្លៃអនុគ្រោះពិសេស ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពេលយប់ ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្មនេះ ។

អាស្រ័យហេតុនេះ សូមលោកឧកញ៉ា លោក/លោកស្រី ជាអ្នកកាន់អាជ្ញាបណ្ណផ្គត់ផ្គង់អគ្គិសនី និងអ្នកប្រើប្រាស់គ្រប់ប្រភេទក្នុងវិស័យកសិកម្មទាំងអស់ មេត្តាជ្រាប និងអនុវត្តសេចក្តីណែនាំនេះ ឲ្យមានប្រសិទ្ធភាព ។

ថ្ងៃពុធ ៧កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**យឹម ទិសិដ្ឋ**

ចម្លងជូន

-ក្រសួងរ៉ែ និងថាមពល

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
"ដើម្បីជូនជ្រាប"

-អគ្គិសនីកម្ពុជា

-មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

-អ្នកកាន់អាជ្ញាបណ្ណពាក់ព័ន្ធ
"ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ "ក"**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

៙៙៙ ❋ ៙៙៙

គំរូសម្រាប់អតិថិជនចាស់

**គោរពជូន**

**លោកប្រធានក្រុមហ៊ុន/សហគ្រាស/ឈ្មោះអ្នកផ្គត់ផ្គង់អគ្គិសនី**

**កម្មវត្ថុ ៖** សំណើសុំអនុញ្ញាតប្តូរប្រភេទអ្នកប្រើប្រាស់ ទៅជាអ្នកប្រើប្រាស់ប្រភេទកសិកម្ម ដែលទទួលបានថ្លៃអនុគ្រោះពិសេស៤៨០រ/គីឡូវ៉ាត់ម៉ោងសម្រាប់ការប្រើប្រាស់ពីម៉ោង ៩:០០យប់ដល់ម៉ោង ៧:០០ព្រឹក ។

**យោង ៖** ឯកសារស្នើសុំបន្តចរន្ត/វិក្ក័យបត្រអគ្គិសនី ។

សេចក្តីដូចក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនលោកប្រធានក្រុមហ៊ុន/សហគ្រាស/ឈ្មោះអ្នកផ្គត់ផ្គង់អគ្គិសនី មេត្តាជ្រាបថា ខ្ញុំឈ្មោះ ........................................... ដែលមានលេខសម្គាល់អតិថិជន .......................... កំពុងប្រើប្រាស់អគ្គិសនីនៅភូមិ ............ ឃុំ ................ ស្រុក ................ ខេត្ត .............. កម្លាំង ......អាំពែរ/គីឡូវ៉ុលអាំពែរ បច្ចុប្បន្ន ជាអ្នកប្រើប្រាស់ប្រភេទ ...................................... ។ ពេលនេះ ខ្ញុំស្នើសុំប្តូរប្រភេទអ្នកប្រើប្រាស់ ទៅជាអ្នកប្រើប្រាស់ប្រភេទកសិកម្ម (រោងម៉ាស៊ីនកិនស្រូវ ចិញ្ចឹមត្រី រោងចក្រគំណាប់ស្វាយ .........) ដើម្បីទទួលបានថ្លៃអនុគ្រោះពិសេស ៤៨០រ/គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពីម៉ោង៩:០០យប់ដល់ម៉ោង ៧:០០ព្រឹក ។

អាស្រ័យហេតុនេះ សូមលោកប្រធានក្រុមហ៊ុន/សហគ្រាស/ឈ្មោះអ្នកផ្គត់ផ្គង់អគ្គិសនីពិនិត្យ និងសម្រេច ដោយអនុគ្រោះ ។

សូមលោកប្រធានក្រុមហ៊ុន/សហគ្រាស/ឈ្មោះអ្នកផ្គត់ផ្គង់អគ្គិសនី មេត្តាទទួលនូវសេចក្តីគោរពដ៏ស្មោះអំពីខ្ញុំ ។

ថ្ងៃ......................... ខែ.............. ឆ្នាំ........ ព.ស.២៥៦.....

ធ្វើនៅ................. , ថ្ងៃទី......... ខែ...............ឆ្នាំ២០២......

**ស្នាមមេដៃ ឬហត្ថលេខានិងត្រា**
**ឈ្មោះអតិថិជន**



**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

**ឧបសម្ព័ន្ធ "ខ"**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៣៣ ❋ ៣៣៣

គំរូសម្រាប់អតិថិជនចាស់

ក្រុមហ៊ុន/សហគ្រាស/...........

លេខ .............................

ធ្វើនៅ................ , ថ្ងៃទី......... ខែ...............ឆ្នាំ២០២.....

**គោរពជូន**

**លោកអគ្គនាយករង ទទួលបន្ទុកមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ**

**កម្មវត្ថុ ៖** សំណើសុំអនុញ្ញាតប្តូរប្រភេទអ្នកប្រើប្រាស់ ទៅជាអ្នកប្រើប្រាស់ប្រភេទកសិកម្ម ដែលទទួលបានថ្លៃអនុគ្រោះពិសេស ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ។

**យោង ៖** ឯកសារស្នើសុំបន្តចរន្តរបស់អតិថិជន ។

សេចក្តីដូចក្នុងកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំមានកិត្តិយសសូមជម្រាបជូនលោកអគ្គនាយករង ម.អ.ជ. មេត្តា ជ្រាបថា អតិថិជន ៖

១. ឈ្មោះ .... ដែលមានទីតាំងនៅភូមិ ... ឃុំ ... ស្រុក .... ខេត្ត .... កម្លាំង ....អាំពែរ/គីឡូវ៉ុលអាំពែរ បច្ចុប្បន្ន ជាអ្នកប្រើប្រាស់ប្រភេទ ... ។

២. ឈ្មោះ .... ដែលមានទីតាំងនៅភូមិ ... ឃុំ ... ស្រុក .... ខេត្ត .... កម្លាំង ....អាំពែរ/គីឡូវ៉ុលអាំពែរ បច្ចុប្បន្ន ជាអ្នកប្រើប្រាស់ប្រភេទ ... ។

បានស្នើសុំប្តូរប្រភេទអ្នកប្រើប្រាស់ ទៅជាអ្នកប្រើប្រាស់ប្រភេទកសិកម្ម ដើម្បីទទួលបានថ្លៃអនុគ្រោះពិសេស ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ។ តាមការចុះពិនិត្យជាក់ស្តែងដល់ទីតាំងប្រើប្រាស់របស់យើងខ្ញុំឃើញថា អតិថិជនខាងលើ ពិតជាអតិថិជនប្រភេទកសិកម្ម (រោងម៉ាស៊ីនកិនស្រូវ ចិញ្ចឹមត្រី រោងចក្រកំណាប់ស្វាយ ........) ស្របតាមគោលការណ៍កំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ សូមជូនឯកសារស្នើសុំបន្តចរន្តរបស់អតិថិជន ។

អាស្រ័យហេតុនេះ សូមលោកអគ្គនាយករង ម.អ.ជ. មេត្តាពិនិត្យ និងសម្រេច ដោយក្តីអនុគ្រោះ ។

សូមលោកអគ្គនាយករង មេត្តាទទួលនូវសេចក្តីគោរពដ៏ស្មោះអំពីយើងខ្ញុំ ។

**អ្នកកាន់អាជ្ញាបណ្ណ**

ចម្លងជូន ៖

-អាជ្ញាធរអគ្គិសនីកម្ពុជា

-ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ "គ"**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គំរូសម្រាប់អតិថិជនថ្មី**

ក្រុមហ៊ុន/សហគ្រាស/...........

លេខ ............................

ធ្វើនៅ................ , ថ្ងៃទី......... ខែ..............ឆ្នាំ២០២......

**គោរពជូន**
**លោកអគ្គនាយករង ទទួលបន្ទុកមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ**

**កម្មវត្ថុ ៖** សំណើសុំអនុញ្ញាតបន្តចរន្តអគ្គិសនីឲ្យអតិថិជន សម្រាប់វិស័យកសិកម្ម ដែលទទួលបានថ្លៃអនុគ្រោះពិសេស ៤៨០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ។

**យោង ៖** ឯកសារស្នើសុំបន្តចរន្តរបស់អតិថិជន ។

សេចក្ដីដូចក្នុងកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំមានកិត្តិយសសូមជម្រាបជូនលោកអគ្គនាយករង ម.អ.ជ. មេត្តាជ្រាបថា អតិថិជន ៖

១.ឈ្មោះ .... ដែលមានទីតាំងនៅភូមិ ... ឃុំ ... ស្រុក .... ខេត្ត .... ស្នើសុំកម្លាំង ....អាំពែរ/គីឡូវ៉ុលអាំពែរ

២.ឈ្មោះ .... ដែលមានទីតាំងនៅភូមិ ... ឃុំ ... ស្រុក .... ខេត្ត .... ស្នើសុំកម្លាំង ....អាំពែរ/គីឡូវ៉ុលអាំពែរ

បានស្នើសុំប្រើប្រាស់អគ្គិសនីប្រភេទកសិកម្ម ដើម្បីទទួលបានថ្លៃអនុគ្រោះពិសេស ៤៨០ រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក ។ តាមការចុះពិនិត្យជាក់ស្ដែងដល់ទីតាំងប្រើប្រាស់របស់យើងខ្ញុំឃើញថា អតិថិជនខាងលើ ពិតជាអតិថិជនប្រភេទកសិកម្ម (រោងម៉ាស៊ីនកិនស្រូវ ចិញ្ចឹមត្រី រោងចក្រតំណាប់ស្វាយ ........) ស្របតាមគោលការណ៍កំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ សូមជូនឯកសារស្នើសុំបន្តចរន្តរបស់អតិថិជន ។

អាស្រ័យហេតុនេះ សូមលោកអគ្គនាយករង ម.អ.ជ. មេត្តាពិនិត្យ និងសម្រេច ដោយក្ដីអនុគ្រោះ ។

សូមលោកអគ្គនាយករង មេត្តាទទួលនូវសេចក្ដីគោរពដ៏ស្មោះអំពីយើងខ្ញុំ ។

**អ្នកកាន់អាជ្ញាបណ្ណ**

ចម្លងជូន ៖
-អាជ្ញាធរអគ្គិសនីកម្ពុជា
-ឯកសារ-កាលប្បវត្តិ